# អភិបាលកិច្ចទីប្រជុំជនក្នុងបរិបទវិមជ្ឈការ នៅកម្ពុជា៖ ប្រធានបទមិនសូវមានគេស្រាវជ្រាវ?[១]

## សេចក្ដីផ្ដើម

អត្ថបទនេះព្យាយាមពន្យល់ថា អភិបាលកិច្ចទីប្រជុំជននៅក្នុងកំណែទម្រង់វិមជ្ឈការនៅកម្ពុជា គួរមានការសិក្សាស៊ីជម្រៅថែមទៀត។ មានការកែប្រែផ្នែកឥរិយាបថ និងផ្នែកស្ថាប័នជាច្រើនបានកើតឡើង បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី១ កាលពីមួយទសវត្សរ៍កន្លងទៅ។ ការសិក្សាលើឯកសារមានស្រាប់បង្ហាញថា ទោះជាកំណែទម្រង់វិមជ្ឈការបែបប្រជាធិបតេយ្យនៅកម្ពុជា ទទួលបានការយកចិត្តទុកដាក់ច្រើនក្ដី ក៏ការស្រាវជ្រាវភាគច្រើនពីប្រធានបទនេះ មិនបានគិតគូរដល់ស្ថានភាពជាក់ស្ដែងនៅតំបន់ទីប្រជុំជនទេ។ បទសម្ភាសន៍មួយចំនួនជាមួយអ្នកធ្វើគោលនយោបាយ និងសមាជិកក្រុមប្រឹក្សា ឃុំសង្កាត់ ដែលជាផ្នែកមួយនៃការស្រាវជ្រាវបឋមអំពីអភិបាលកិច្ចទីប្រជុំជន បានបង្ហាញពីសារៈសំខាន់នៃការពិនិត្យអង្កេតទៅតាមប្រភេទទីតាំងភូមិសាស្ត្រផ្សេងៗនៅកម្ពុជា ជាពិសេស តំបន់ជនបទ ធៀបនឹងទីប្រជុំជន ដើម្បីបង្កើនប្រសិទ្ធភាពគោលនយោបាយឲ្យបានជាអតិបរមា នៅតាមទីតាំងខុសៗគ្នាក្នុងដែនសមត្ថកិច្ចរបស់រដ្ឋអំណាចមូលដ្ឋាន។ អត្ថបទនេះចាប់ផ្ដើមឡើងដោយការកំណត់និយមន័យ "ទីប្រជុំជន" និង "អភិបាលកិច្ចទីប្រជុំជន" រួចធ្វើការត្រួតពិនិត្យឡើងវិញត្រួសៗពីវិមជ្ឈការនៅកម្ពុជា។ ផ្នែកទី៣ បង្ហាញពីមូលហេតុ និងសំណួរនៃការស្រាវជ្រាវ ព្រមទាំងក្របខ័ណ្ឌស្រាវជ្រាវសម្រាប់ប្រើជាផែនទីបង្ហាញផ្លូវចំពោះការស្រាវជ្រាវនេះ។ ផ្នែកបន្ទាប់មកទៀតបង្ហាញពីចំណេះដឹងទទួលបានពីការចុះសិក្សាដល់កន្លែងជាដំបូងៗ ហើយនៅចុងបញ្ចប់មានសេចក្ដីសន្និដ្ឋានអំពីតម្រូវការគោលនយោបាយដែលយកចិត្តទុកដាក់ពីបញ្ហាទីតាំង ដើម្បីដោះស្រាយបញ្ហាតែងតែជួបប្រទះនៅតំបន់ប្រជុំជន ។

## នៅក្នុងអភិបាលកិច្ចទីប្រជុំជន តើ "ទីប្រជុំជន" ជាអ្វី?

ដោយសារអត្ថបទនេះផ្ដោតលើតំបន់ទីប្រជុំជន ដូច្នេះគួរបញ្ជាក់ពីអត្ថន័យពាក្យ "ទីប្រជុំជន" នៅក្នុងបរិបទអភិបាលកិច្ចទីប្រជុំជន។ គេអាចកំណត់និយមន័យ ទីប្រជុំជន តាមរយៈលក្ខណៈវិនិច្ឆ័យផ្នែករដ្ឋបាល ដង់ស៊ីតេប្រជាជន មុខងារសេដ្ឋកិច្ច ឬហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជាដើម។ ទីប្រជុំជនជាច្រើននៅទ្វីបអាស៊ី រួមទាំងនៅកម្ពុជាផង ក៏ត្រូវបានឲ្យនិយមន័យដូច្នេះដែរ។ នៅកម្ពុជា និយមន័យមានស្រាប់មួយដែលក្រសួងផែនការបានយកមកប្រើ ក្នុងពេលធ្វើចំណាត់ថ្នាក់តំបន់ទីប្រជុំជនជាថ្មីនៅឆ្នាំ២០០៤ គឺបានកំណត់តំបន់ទីប្រជុំជន ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យបី គឺ៖ ១) មានដង់ស៊ីតេប្រជាជនលើសពី ២០០ នាក់/គម$^{២}$ ២) មានអត្រាបុរសធ្វើការក្នុងវិស័យកសិកម្ម តិចជាង ៥0% និង ៣) មានចំនួនប្រជាជន សរុបលើសពី ២០០០នាក់ (NIS 2004)[២]។ បញ្ហាចោទលើនិយមន័យនេះ គឺវាពុំមានការទទួលស្គាល់ ជាសកលពីគ្រប់ស្ថាប័នរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានាទេ។ ក្នុងអត្ថបទនេះ តំបន់ទីប្រជុំជនមិនមែនគ្រាន់តែសំគាល់ឡើងតាម លក្ខណៈហេដ្ឋារចនាសម្ព័ន្ធ ឬក៏ចំនួនប្រជាជននោះទេ ប៉ុន្តែថែមទាំងទៅតាមលក្ខណៈវិនិច្ឆ័យដែលមិនអាចមើលឃើញផ្សេងទៀត ពោលគឺ តាមវិធីសាស្ត្រផ្នែកនរវិទ្យាសម្រាប់បរិបទទីប្រជុំជន ដែលផ្ដោតសំខាន់ទៅលើដង់ស៊ីតេខ្ពស់នៃទំនាក់ទំនងសង្គម នៅក្នុងទីតាំងនីមួយៗ (Gutkind 1974)។ នៅក្នុងនរវិទ្យា ដង់ស៊ីតេប្រជាជនមិនមែនជាចំណុចសំខាន់ទេ ប៉ុន្តែគឺ ដង់ស៊ីតេទំនាក់ទំនងសង្គម។ ការលើកយកគំនិតយល់ដឹងពី ទំនាក់ទំនងសង្គម មកជជែកវែកញែកបែបនេះ បានផ្ដល់ពន្លឺថ្មីមួយដល់ការពិភាក្សាពីអភិបាលកិច្ច និងបំផុសសំណួរថា តើគេគួរកំណត់ឡើងវិញនូវនិយមន័យនៃពាក្យអភិបាលកិច្ចទីប្រជុំជន ឬយ៉ាងណា។

គេអាចឲ្យនិយមន័យអភិបាលកិច្ចយ៉ាងសាមញ្ញថាជា "ការប្រើប្រាស់សិទ្ធិអំណាចខាងសេដ្ឋកិច្ច នយោបាយ និង រដ្ឋបាលដើម្បីគ្រប់គ្រងកិច្ចការប្រទេសមួយនៅគ្រប់កម្រិត" (UNDP 2003:170)។ ដូច្នេះ តើអភិបាលកិច្ចទីប្រជុំជន សំដៅដល់ការគ្រប់គ្រងកិច្ចការទីប្រជុំជនមែនទេ? និយមន័យរបស់ UNESCO (ដកស្រង់ពី Kaufman *et al.* 2005: 7) បានចាត់ទុកអភិបាលកិច្ចទីប្រជុំជនជា "ដំណើរការតម្រង់ទិស និងគិតគូរពីទំនាក់ទំនងផ្សេងៗ រវាងអ្នកពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ។ វាមានបញ្ចូលនូវយុទ្ធសាស្ត្រពីក្រោមឡើងលើ និងពីលើចុះក្រោម ដើម្បីសម្រួលដល់ការចូលរួមរបស់សហគមន៍ពាក់ព័ន្ធ ទំនាក់ទំនងរវាងតួអង្គនានា ការធ្វើការសម្រេចចិត្តដោយមានតម្លាភាព និងការកែច្នៃបែបថ្មីនូវយុទ្ធសាស្ត្រគោលនយោបាយគ្រប់គ្រងទីប្រជុំជន"។ ចំណុចស្នូលនៃនិយមន័យនេះ គឺទំនាក់ទំនងរវាងតួអង្គផ្សេងៗ មានជាអាទិ៍ រដ្ឋាភិបាល ប្រជាពលរដ្ឋ អ្នកពាក់ព័ន្ធនានា ក៏ដូចជា វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល (NGOs)។ ការគិតគូរយ៉ាងទូលាយពីតួអង្គផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងអភិបាលកិច្ច ក៏មានអ្នកស្រាវជ្រាវជាច្រើនទៀតយល់ស្របដែរ (Ojendal & Dellnas 2010)។ ដូចមានបង្ហាញខាងលើ ទំនាក់ទំនងទាំងនេះហាក់កើតមានញឹកញាប់នៅក្នុងបរិបទទីប្រជុំជន។ និយមន័យនេះជាក្របខ័ណ្ឌរួមមួយសម្រាប់ស្វែងយល់ពី អភិបាលកិច្ចទីក្រុងជាទូទៅ ប៉ុន្តែវាទូលំទូលាយបន្តិច ដោយសារមិនមានបញ្ជាក់ច្បាស់លាស់ពី កត្តាដែលជះឥទ្ធិពលទៅលើទំនាក់ទំនងប្រចាំថ្ងៃ រវាង

---

[១] អត្ថបទនេះរៀបរៀងឡើងដោយលោក ឈាត ស្រ៊ាង អាន សុវត្ថា ជាអ្នកស្រាវជ្រាវ និងលោក គឹម សេតារា ជាអ្នកស្រាវជ្រាវជាន់ខ្ពស់ នៃកម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់សាធារណៈនៃវិទ្យាស្ថាន CDRI។

[២] ឃុំ គឺជាឯកតាត្រូវយកមកគណនា ដើម្បីកំណត់ថា តើតំបន់នោះស័ក្តិសមជា "ទីប្រជុំជន" ឬ "ជនបទ"។ ធម្មតា សង្កាត់ សំដៅដល់ ឃុំរបស់ទីក្រុង ប៉ុន្តែបើប្រើប្រាស់និយមន័យឆ្នាំ២០០៤នោះ សង្កាត់នៅក្នុងក្រុងទាំង ២៦ នៅកម្ពុជាមិនសុទ្ធតែគ្រប់លក្ខណៈជាតំបន់ទីប្រជុំជនទាំងអស់ទេ។ សូមមើល http://db.ncdd.gov.kh/cdbonline/home/index.castle (accessed 26 May 2012)

អ្នកពាក់ព័ន្ធទាំងនោះ។ ទោះបីនគរូបនីយកម្មនៅកម្ពុជានៅមានលក្ខណៈក្មេងខ្ចី ហើយតំបន់ទីប្រជុំជននានាប្រហែលអាចនៅរក្សាបាននូវ លក្ខណៈចាំបាច់មួយចំនួនសម្រាប់ឲ្យអភិបាលកិច្ចមូលដ្ឋានអនុវត្តបានជោគជ័យក្តី ក៏អត្ថបទនេះយល់ស្រប ជាមួយការសិក្សារបស់ Ojendal and Dellnas (2010) ដែលថា ការយកគំរូអភិបាលកិច្ចមូលដ្ឋានមួយទៅ អនុវត្តនៅក្នុងបរិបទទីក្រុងទំនើបមួយ គឺជាការពិបាក។

## អធិប្បាយសង្ខេបពីបរិបទវិមជ្ឈការ

កម្ពុជាបានអនុវត្តកំណែទម្រង់វិមជ្ឈការ ដើម្បីដោះស្រាយបញ្ហាភាពពេញច្បាប់ផ្នែកនយោបាយ និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច តាមការបង្កឲ្យមានការចូលរួមពីថ្នាក់មូលដ្ឋានក្នុងការសម្រេចចិត្តផ្សេងៗ និងដាក់ឲ្យអាជ្ញាធរមូលដ្ឋានមានគណនេយ្យភាព។ ការបោះឆ្នោតឃុំសង្កាត់លើកទី១ បានធ្វើឡើងក្នុងឆ្នាំ២០០២។ សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវបានបោះឆ្នោតជ្រើសតាំងដោយផ្ទាល់ពីប្រជាជន សម្រាប់អាណត្តិប្រាំឆ្នាំ ស្របតាមប្រព័ន្ធបោះឆ្នោតសមាមាត្រផ្អែកលើបញ្ជីគណបក្ស។ គោលដៅជាក់លាក់នៃកំណែទម្រង់ រួមមាន ពង្រឹងរបបប្រជាធិបតេយ្យ កែលំអការផ្តល់សេវាដល់ប្រជាជនមូលដ្ឋាន និង លើកកម្ពស់ជីវភាពប្រជាជនមូលដ្ឋាន (RGC 2005)។ ចាប់ពីឆ្នាំ២០០៩មក សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ជាអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត/ក្រុង។ ជាគោលការណ៍ សមាជិកក្រុមប្រឹក្សាខេត្ត/ក្រុង ត្រូវមានគណនេយ្យភាពចំពោះ ក្រុមប្រឹក្សាឃុំសង្កាត់ដែលជាអ្នកបោះឆ្នោតជ្រើសតាំងខ្លួនឡើង (ច្បាប់រៀបចំអង្គការឆ្នាំ២០០៨) ប៉ុន្តែក្នុងការពិតជាក់ស្តែង រឿងនេះនៅជាបញ្ហាចោទនៅឡើយ (Hughes & Devas 2007; Chheat *et al.* 2011)។ ក្នុងក្របខ័ណ្ឌថ្មីនេះ ក្រុមប្រឹក្សាថ្នាក់មូលដ្ឋានត្រូវពិភាក្សា និងតំណាងឲ្យគំនិតរបស់ប្រជាជនមូលដ្ឋាន ក្នុងការធ្វើផែនការក្នុងមូលដ្ឋាន ដើម្បីឲ្យស្របតាមតម្រូវការក្នុងមូលដ្ឋាន។ ច្បាប់ចែងថា ពួកគេត្រូវមានគណនេយ្យភាពចំពោះប្រជាជន ប៉ុន្តែបញ្ហាធនធានហិរញ្ញវត្ថុមិនគ្រប់គ្រាន់ បានរារាំងពួកគេមិនឲ្យមានគណនេយ្យភាពពិតៗ ចំពោះអ្នកបោះឆ្នោតឲ្យខ្លួន។ ការផ្ទេរថវិកាដែលមានតិចតួចបែបនេះ មានន័យថា វិមជ្ឈការហិរញ្ញវត្ថុមិនទាន់កើតមានជាក់ស្តែងនៅឡើយទេ (Pak 2011)។

ក្នុងពេលដែល ការអនុវត្តកំណែទម្រង់រដ្ឋបាល និងនយោបាយដ៏មោះមុតនេះ បានទទួលការកោតសរសើរយ៉ាងខ្លាំង ព្រោះអាចចូលរួមចំណែកដល់ ការអភិវឌ្ឍដែលមានមូលដ្ឋានទ្រឹស្តីជួយទ្រទ្រង់ជាក់លាក់ (Öjendal 2002, 2005) គឺនៅមានបញ្ហាប្រឈមមួយចំនួនទៀត ដូចជាក្របខ័ណ្ឌច្បាប់ ការរចនារៀបចំស្ថាប័ន និងយន្តការសម្រាប់ឲ្យរដ្ឋាភិបាលថ្នាក់ក្រោមជាតិធ្វើការសម្របសម្រួល និងជួយក្រុមប្រឹក្សាឃុំ (Rusten *et al.* 2004)។ ទោះបីជាកំណែទម្រង់នេះ ទទួលបានការសរសើរចំពោះការរួមចំណែកពង្រឹងរបបប្រជាធិបតេយ្យ និងការកាត់បន្ថយភាពក្រីក្រនៅមូលដ្ឋាន (Öjendal & Kim 2006, 2011, 2011a; Kim 2011) និងបើកឱកាសឲ្យស្ត្រីបានចូលរួមនៅក្នុងការងារអភិបាលកិច្ចមូលដ្ឋានក្តី ប៉ុន្តែនៅមានការងារជាច្រើនទៀតនៃកំណែទម្រង់នេះដែលត្រូវការ ការធ្វើឲ្យប្រសើរឡើងថែមទៀត (Kim 2011; Manor 2008)។ ទោះបីជាក្នុងក្របខ័ណ្ឌច្បាប់មានចែងច្បាស់ពីអាណត្តិ និងមុខងារក្តី ក៏ឃុំសង្កាត់បាននិងកំពុងអនុវត្តត្រឹមតែមុខងារតូចតាច ដូចជាការធ្វើបញ្ជីអត្រានុកូលដ្ឋាន ការដោះស្រាយទំនាស់សាមញ្ញៗ និងការប្រមូលទិន្នន័យ សេដ្ឋកិច្ច-សង្គមកិច្ចសម្រាប់ស្ថាប័នរដ្ឋផ្សេងៗប៉ុណ្ណោះ (Kim & Henke 2005)។ បញ្ហាដែលមានលក្ខណៈ រសើបខាងនយោបាយ ដូចជាការគ្រប់គ្រងដីធ្លី ព្រៃឈើ និងធនធានធម្មជាតិជាដើម បច្ចុប្បន្នខាងឃុំសង្កាត់ មិនទាន់អាចឈោងដល់នៅឡើយទេ បើទោះជាបទបញ្ញត្តិច្បាប់បានកំណត់ឲ្យធ្វើប្រតិភូកម្មទំនួលខុសត្រូវ និងសិទ្ធិអំណាចប្រភេទនេះទៅឲ្យពួកគេ ក្តី (Kim & Öjendal 2011)។

ការអនុវត្តកំណែទម្រង់វិមជ្ឈការនេះ កំពុងតែកើតឡើងនៅក្នុងពេលដែលប្រទេសកម្ពុជា កំពុងមានការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចយ៉ាងខ្លាំង ទាំងវិជ្ជមាន និងអវិជ្ជមាន។ តាមការព្យាករណ៍ ចំនួនប្រជាជនកម្ពុជានៅទីប្រជុំជន នឹងកើនឡើងខ្ពស់ដល់ ៣,៥% ក្នុងមួយឆ្នាំ ឬកើន ៣៥% ដល់ប្រាំបីលាននាក់នៅត្រឹមឆ្នាំ២០៣០។ នគរូបនីយកម្មឆាប់រហ័ស នាំឲ្យចំណុចខ្វះខាតកើនឡើងនៅតំបន់ទីប្រជុំជន ដូចជាបញ្ហា ការផ្តល់សេវាសាធារណៈមិនបានគ្រប់គ្រាន់ ការតាំងទីលំនៅខុសច្បាប់ និងការបំពុលបរិស្ថានជាដើម (Benghong 2006; OCM, undated)។ គេជឿថា វិមជ្ឈការនឹងជួយដោះស្រាយបញ្ហាទាំងនេះ (Benghong 2006; Devas 2004) ប៉ុន្តែនៅផ្ទាល់កន្លែងគេអាចអនុវត្តបានពិតជាក់ស្តែងប៉ុណ្ណា ពេលនេះមិនទាន់អាចវាយតម្លៃបាននៅឡើយទេ។

## ហេតុអ្វីត្រូវមានអភិបាលកិច្ចទីប្រជុំជន?

ទោះបីជា នៅកម្ពុជាពេលថ្មីៗនេះមានកំណើនសេដ្ឋកិច្ចដ៏លឿនក៏ពិតមែន ប៉ុន្តែកម្ពុជានៅតែជាប្រទេសកំពុងអភិវឌ្ឍន៍មួយ ដែលត្រូវការជំនួយអភិវឌ្ឍន៍ជាច្រើននៅឡើយ។ ចំណុចគួរបារម្ភមួយទៀតដែលត្រូវកត់សម្គាល់ គឺជំនួយអភិវឌ្ឍន៍ភាគច្រើនតម្រង់ទិសទៅរកតែតំបន់ជនបទដែលគេឃើញថាមានភាពក្រីក្រច្រើនជាងគេ ហើយមើលរំលងភាពក្រីក្រនៅតំបន់ទីប្រជុំជន។ បើសិនចង់ដោះស្រាយ បញ្ហាផ្សេងៗនៅតំបន់ទីប្រជុំជន ឲ្យបានត្រឹមត្រូវ ស្ថាប័នអភិបាលកិច្ចមូលដ្ឋាននៅតំបន់ទីប្រជុំជនត្រូវតែមានសមត្ថភាពច្រើនជាងនេះ ហើយគេត្រូវមានគោលនយោបាយវិមជ្ឈការដែលយកចិត្តទុកដាក់ពី លក្ខណៈទីតាំងភូមិសាស្ត្រខុសគ្នា។ ក្នុងផ្នែកនេះ យើងនឹងពិភាក្សាពីហេតុផលមួយចំនួនដែលគេគួរបង្កើនការយកចិត្តទុកដាក់ ទៅលើអភិបាលកិច្ចតំបន់ទីប្រជុំជន។

ទី១ ការសិក្សាសំខាន់ៗជាច្រើន បានបង្ហាញពីកង្វះចំណាប់អារម្មណ៍លើអភិបាលកិច្ចទីប្រជុំជន នៅក្នុងការស្រាវជ្រាវស្តីពីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការនៅកម្ពុជា។ អត្ថបទរបស់ Blunt and Turner (2005) ដែលរៃកញ្ញែកថា បរិបទស្ថាប័ន និងសង្គមវប្បធម៌នៅកម្ពុជា មិនសូវសមស្របនឹងកំណែទម្រង់វិមជ្ឈការនោះ ហាក់មិនបានយកចិត្តទុកដាក់សោះពីភាពខុសប្លែកគ្នារវាងតំបន់ទីប្រជុំជន និងជនបទ។ ស្រដៀង

គ្នានេះដែរ ការសិក្សាវាយតម្លៃរបស់ Smoke and Morrison (2008) ពីដំណើរការវិមជ្ឈការនៅកម្ពុជា បានមើលរំលងទិដ្ឋភាពជាក់ស្ដែងនៅតំបន់ទីប្រជុំជន។ របាយការណ៍នោះពិភាក្សាថា តើកំណែទម្រង់វិមជ្ឈការនៅកម្ពុជា ជាមធ្យោបាយមួយសម្រាប់ពង្រឹងអំណាចរបស់រដ្ឋាភិបាលមជ្ឈឹម ឬក៏ បង្កើតនូវវេទិកាមួយ ដើម្បីឲ្យមានគណនេយ្យភាពពីលើចុះក្រោម ពោលគឺ ចំពោះដល់ប្រជាពលរដ្ឋឬយ៉ាងណា ប៉ុន្តែរបាយការណ៍នេះ ហាក់ដូចបានច្របាច់បូកបញ្ចូលរួមគ្នានូវស្ថានភាពខុសគ្នារវាងតំបន់ ទីប្រជុំជន និងជនបទ ហើយមិនបានពិនិត្យពីតថភាពជារួមនៅទីប្រជុំជនដែលអាចជំរុញ ឬរារាំងដល់ការអនុវត្តអភិបាលកិច្ចតំបន់ទីប្រជុំជនក្នុងបរិបទវិមជ្ឈការនោះទេ។ គេក៏សង្កេតឃើញមានអារម្មណ៍សុទិដ្ឋិនិយមខ្លាំងមួយ នៅក្នុងរបាយការណ៍របស់ Ojendal and Kim (2011) ស្ដីពីដំណើរជឿនលឿនទៅកាន់ វិមជ្ឈការតាមបែបប្រជាធិបតេយ្យពិតៗនៅកម្ពុជា ប៉ុន្តែស្ថានភាពជាក់ស្ដែងនៅតំបន់ទីប្រជុំជន មិនត្រូវបានគេបង្ហាញនៅក្នុង រូបភាពនៃសុទិដ្ឋិនិយមនោះទេ។ ពួកគេរំលែកញែកថា ទិដ្ឋភាពសុទិដ្ឋិនិយមនេះ អាចផុសចេញពីធាតុពិតដែលកំណែទម្រង់ បានកើតចេញពីបទពិសោធន៍នៅកម្ពុជាផ្ទាល់ (Ojendal & Kim 2011) និងមិនមែននាំចូលទាំងស្រុងពីបរទេសនោះទេ។ ការសិក្សាទាំងនេះមានចំណុចខ្សោយរួមមួយគឺកង្វះ ឬការបំភ្លេចចោលនូវទិដ្ឋភាពនៃកន្លែងនៅតំបន់ទីប្រជុំជននៅក្នុងការវិភាគអំពីបាតុភូតសង្គម នយោបាយ ឬក៏បញ្ហាផ្សេងៗខាងទ្រឹស្ដីដែលពួកគេបានធ្វើការសិក្សាស្រាវជ្រាវ។ អត្ថបទនេះលើកមកពិភាក្សាតែ ឧទាហរណ៍មួយចំនួនតូចប៉ុណ្ណោះ ប៉ុន្តែការវែកញែកពីបញ្ហាខាងលើ ឃើញមាននៅក្នុងឯកសារមានស្រាប់ទាំងអស់ដែលពិនិត្យពីរឿងនេះ ហើយវាបង្ហាញថា ក្នុងផ្នែកស្រាវជ្រាវពីរដ្ឋបាលមូលដ្ឋាននៅកម្ពុជានៅមានចន្លោះប្រហោងមួយត្រូវបំពេញដែលទាក់ទងនឹងអភិបាលកិច្ចក្នុងបរិបទទីប្រជុំជន។

ទី២ គេមិនទាន់ដឹងទេថា តើគោលនយោបាយវិមជ្ឈការដែលនាំឲ្យមាន ការបង្កើតរចនាសម្ព័ន្ធរដ្ឋាភិបាលថ្នាក់ក្រោមជាតិថ្មីនោះបានយកចិត្តទុកដាក់កម្រិតណាពីភាពស្មុគស្មាញនិងតថភាពជាក់ស្ដែងនៃបរិបទទីប្រជុំជននោះទេ។ ក្រុមប្រឹក្សាស្រុក/ខេត្តថ្មីព្រមទាំងតួនាទី និងមុខងាររបស់ពួកគេ ត្រូវបានកំណត់ឡើងនៅក្នុងបរិបទនៃនគរូបនីយកម្មឆាប់រហ័ស ដែលកើតមានឡើងស្របគ្នានឹងកំណើនសេដ្ឋកិច្ចយ៉ាងទៀងទាត់នៅកម្ពុជា។ ភាពក្រីក្រនៅតំបន់ទីក្រុង គឺជាបាតុភូតផ្នែករចនាសម្ព័ន្ធមួយដែលមួយផ្នែកគឺ ជំរុញឡើងដោយសារសំពាធនៃការបាត់បង់ការងារ និងមធ្យោបាយចិញ្ចឹមជីវិតបែបប្រពៃណីនៅតំបន់ជនបទ និងមួយផ្នែកទៀត គឺដោយសារវត្តមានមធ្យោបាយចិញ្ចឹមជីវិត និងឱកាសសេដ្ឋកិច្ចល្អៗនៅទីក្រុង ដែលកើតមានតាមរយៈការអនុវត្តប្រព័ន្ធសេដ្ឋកិច្ចសេរីនិយមបែបថ្មី។ ជនក្រីក្រនៅទីក្រុងភាគច្រើនរស់នៅក្នុងតំបន់ក្រតោកយ៉ាក ដែលខ្វះខាតទាំងសេវាកម្មជាមូលដ្ឋាន ដោយសារកង្វះខាតសមត្ថភាពរបស់អាជ្ញាធរនៅតំបន់ទីក្រុង។ ការចូលរួមរបស់ប្រជាជនក្នុងការធ្វើផែនការក្នុងមូលដ្ឋាន និងការសម្រេចចិត្តផ្សេងៗដែលអាចជះឥទ្ធិពលទៅលើការរស់នៅរបស់ខ្លួន កម្រទទួលបានការវាយតម្លៃខ្ពស់ពីសំណាក់អាជ្ញាធរតំបន់ទីប្រជុំជនណាស់ ហើយស្ថានភាពនេះបានធ្វើឲ្យពួកគេកាន់តែខ្សត់ខ្សោយសិទ្ធិអំណាចថែមទៀត (Devas 2004)។ បើគេធ្វើការពិនិត្យម៉ត់ចត់ទៅលើ កំណែទម្រង់របស់កម្ពុជាដែលប្រព្រឹត្តទៅនៅក្នុងតំបន់ទីប្រជុំជន គេនឹងអាចជួយបំភ្លឺពីការចូលរួមរបស់ប្រជាពលរដ្ឋ និងថាតើការចូលរួមនោះមានអត្ថន័យយ៉ាងណា។

ទី៣ ចំណុចថា តើរដ្ឋាភិបាលត្រូវធ្វើអ្វីខ្លះ ដើម្បីធានាឲ្យអនុវត្តគោលនយោបាយវិមជ្ឈការបានប្រកបដោយជោគជ័យ ជាពិសេសនៅតំបន់ទីប្រជុំជននោះ ប្រហែលកន្លងមកមិនទាន់ទទួលបានការយកចិត្តទុកដាក់គ្រប់គ្រាន់ទេ[៣]។ ការអនុវត្តកំណែទម្រង់វិមជ្ឈការប្រចាំថ្ងៃរបស់រដ្ឋាភិបាល ហាក់នៅខ្វះអនុសាសន៍ផ្នែកគោលនយោបាយដែលយកចិត្តទុកដាក់ពីទីតាំងផ្សេងៗគ្នា និងគំនិតផ្សេងៗ ក្នុងការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងការរីកលូតលាស់យ៉ាងឆាប់រហ័សនៃទីប្រជុំជន។ ទោះបីជាគេឃើញមានជោគជ័យមួយកម្រិតក្នុងការអភិវឌ្ឍនៅតាមមូលដ្ឋាន តាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងអំឡុងមួយទសវត្សរ៍កន្លងទៅក៏ពិតមែន ប៉ុន្តែគោលនយោបាយសម្រាប់ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ដែល "មើលមិនឃើញពីស្ថានភាពខុសប្លែកគ្នាតាមកន្លែង" គឺមិនបានជួយឲ្យអន្តរាគមន៍របស់រដ្ឋាភិបាលមានប្រសិទ្ធភាពជាអតិបរមាទេ។ ដើម្បីប្ដូរទិសនិន្នាការនេះ UNCDF (2010) បានបញ្ជាក់ពីតម្រូវការឲ្យមានគោលនយោបាយ សម្រាប់ដោះស្រាយបញ្ហាដ៏ជាក់លាក់នានាដែលខេត្ត ឬឃុំសង្កាត់ នៅតំបន់ជនបទ និងនៅទីក្រុងត្រូវប្រឈមមុខ។

## របកគំហើញដាបថមពីមូលដ្ឋាន

ការសិក្សាដល់កន្លែងជាដំបូងៗនៅខេត្តកំពត និងបាត់ដំបងបានបង្កើនការយល់ដឹងរបស់យើងអំពី ស្ថានភាព ភូមិសាស្ត្រ និងសេដ្ឋកិច្ច-សង្គមកិច្ច និងស្ថានភាពបច្ចុប្បន្ននៃរដ្ឋបាលមូលដ្ឋាននៅក្នុងតំបន់ទីប្រជុំជនទាំងនោះ។[៤] ពិតមែនតែការសិក្សាបានរកឃើញនូវការរីកចម្រើនជាសក្ដានុពលក្នុង សមត្ថភាពផ្ដល់សេវាកម្ម និងក្នុងចំណូលហិរញ្ញវត្ថុក្ដី ប៉ុន្តែនៅមានបញ្ហាប្រឈមជាច្រើនទៀតចំពោះរដ្ឋបាលមូលដ្ឋានបច្ចុប្បន្ន ក្នុងការផ្ដល់ និងអនុវត្តសិទ្ធិអំណាចរបស់ខ្លួន នៅតំបន់ទីប្រជុំជន ដែលត្រូវមានការសិក្សាជាលក្ខណៈប្រព័ន្ធ ដើម្បីស្វែងយល់ពីភាពស្មុគស្មាញនៃបញ្ហាទាំងនេះ និងវិធីដោះស្រាយ។

ពិតណាស់ តាមនិយមន័យ ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចនៅតំបន់ទីក្រុង វាខុសប្លែកពី ស្ថានភាពនៅតំបន់ជនបទ ហើយវាបង្ហាញពីទំនាក់ទំនងរវាងតំបន់ទាំងពីរ។ អ្នករស់នៅតំបន់ទីប្រជុំជនភាគច្រើន ជាអ្នកលក់ដូរតូចតាច បុគ្គលិករដ្ឋ ឬពលករស៊ីប្រាក់ខែ ហើយមានច្រើននាក់ជាជនចំណាកស្រុកពីតំបន់ជនបទ។ សមាសភាពនេះចោទបញ្ហាមួយធំចំពោះរដ្ឋាភិបាលក្នុងការប្រមែប្រមូលប្រជាជនឲ្យរួមចំណែកក្នុង ការសម្រេច

[៣] សម្ភាសន៍ជាមួយ ឯកឧត្តម ឡេង វី ប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ថ្ងៃទី៤ ឧសភា ២០១២។

[៤] ការសិក្សាដល់កន្លែង បានធ្វើក្នុងខេត្តកំពត នៅថ្ងៃទី ១៩-២០ មករា ២០១២ និងក្នុងខេត្តបាត់ដំបង នៅថ្ងៃទី ៨-១០ កុម្ភៈ ២០១២។

ចិត្ត និងការពិភាក្សានៅមូលដ្ឋាន។ វាក៏បង្កើតបរិយាកាសមួយដែលក្នុងនេះ អ្នកធូរធារ និងអ្នកមានទំនាក់ទំនងល្អជាមួយថ្នាក់លើ តែងរំពឹងថា ក្រុមប្រឹក្សាមូលដ្ឋានត្រូវអនុវត្តមុខងារតាមបែបណាមួយដែលខ្លួនអាចទទួលយកបាន និងមានផលប្រយោជន៍ចំពោះខ្លួន។ ប៉ុន្តែក្រុមនេះតែងដើររំលងអាជ្ញាធរមូលដ្ឋាន នៅពេលដែលពួកគេត្រូវការសេវាកម្មផ្សេងៗ ដោយសារតែពួកគេមានទំនាក់ទំនងជិតស្និទ្ធជាមួយ ថ្នាក់លើដែលនៅតែក្ដោបក្ដាប់ការងារផ្ដល់សេវាកម្ម។ ទំនាក់ទំនងជិតស្និទ្ធនោះ អាចជំរុញឲ្យមាន កិច្ចសហប្រតិបត្តិការល្អរវាងថ្នាក់ផ្សេងៗនៃរដ្ឋាភិបាលថ្នាក់ក្រោមជាតិ ប៉ុន្តែ វាក៏បង្កើតភាពច្របូកច្របល់ដែរ ដោយសារកង្វះការបញ្ជាក់ឲ្យច្បាស់ពីតួនាទី និងមុខងារនៅតាមថ្នាក់នីមួយៗ។

ដោយសារមានភាពនៅកៀកគ្នា និងទំហំកន្លែង គេត្រូវមានជាចាំបាច់នូវអន្តរកម្ម និងកិច្ចសហប្រតិបត្តិការរវាងសង្កាត់នានាក្នុងការផ្ដល់សេវា និងដោះស្រាយបញ្ហាសង្គម។ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា បំពង់ផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធលូ ផ្លូវថ្នល់ និងបណ្ដាញអគ្គិសនី ដែលជាសេវាសំខាន់បំផុតសម្រាប់ជីវភាពនៅទីប្រជុំជន តម្រូវឲ្យមានកិច្ចសហប្រតិបត្តិការរឹងមាំ និងការយោគយល់គ្នារវាងសង្កាត់នានា។ វិធីសាស្ត្រនេះក៏ចាំបាច់ដែរសម្រាប់ដោះស្រាយបញ្ហា ដូចជា ក្រុមជនពាល បទឧក្រិដ្ឋចំណាកស្រុក និង ការបំពុលបរិស្ថានជាដើម។

ក្នុងយុទ្ធនាការជំរុញឲ្យមាន ការផ្ដល់សេវាបានកាន់តែមានប្រសិទ្ធភាព នៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការនោះ ការិយាល័យសេវាច្រកចេញចូលតែមួយ (OWSO) ត្រូវបានបង្កើតឡើងឲ្យដំណើរការជា យន្តការមួយទៀតសម្រាប់ការផ្ដល់សេវាកម្មនៅកម្រិតក្រុង/សង្កាត់ (Thon *et al.* 2010)។ OWSO មានគំនិតក្នុងការលើកកម្ពស់ ការផ្ដល់សេវាកម្មប្រកបដោយតម្លាភាពនៅក្នុងប្រព័ន្ធរដ្ឋ។ គំរូនេះ អាចចាត់ទុកជា យន្តការមួយដ៏មានប្រសិទ្ធភាព សម្រាប់ការធ្វើប្រតិភូកម្មមុខងារមួយចំនួនទៅឲ្យក្រុមប្រឹក្សាតាមសង្កាត់ ដើម្បីឲ្យពួកគេអាចឆ្លើយតបបានកាន់តែប្រសើរចំពោះតម្រូវការក្នុងមូលដ្ឋាន។ ក្រុមប្រឹក្សាសង្កាត់នៅតំបន់ទីប្រជុំជន ដើរតួនាទីសំខាន់ណាស់ក្នុងការចុះបញ្ជីទ្រព្យសម្បត្តិ និងការប្រមូលពន្ធលើទ្រព្យសម្បត្តិ ដែលទើបនឹងណែនាំថ្មីៗនៅតំបន់ទីប្រជុំជន។ សក្ដានុពលក្នុងការរកចំណូល និងផ្ដល់សេវាកម្មនេះ អាចជួយឲ្យមានការយល់ដឹងកាន់តែប្រសើរអំពីបរិយាកាសសេដ្ឋកិច្ច-សង្គមកិច្ច នៅតំបន់ទីប្រជុំជន ដែលអាជ្ញាធរមូលដ្ឋានត្រូវមានការជាប់ពាក់ព័ន្ធច្រើនណាស់។

ប្រព័ន្ធពហុបក្សនៅកម្ពុជា កន្លងមកបានទទួលរងការរិះគន់ថាជារបបនយោបាយបែបប្រជាធិបតេយ្យ "តែសំបកក្រៅ" នៅកម្ពុជា។ នៅក្នុងរដ្ឋអំណាចថ្នាក់មូលដ្ឋាននៅតំបន់ទីប្រជុំជន ការសម្រេចចិត្តផ្សេងៗក្នុងក្រុមប្រឹក្សា គឺខ្វះខាតនូវការសន្ទនា ឬ ការពិភាក្សាឆ្លងកាត់ក្រុមបក្សនយោបាយផ្សេងៗគ្នា។ សមាជិកក្រុមប្រឹក្សាមកពីគណបក្សប្រឆាំង ជារឿយៗត្រូវគេបំភ្លេចចោលនៅក្នុងការសម្រេចចិត្ត ឬការចូលរួមជាមួយដៃគូអភិវឌ្ឍន៍នានា ដូចជាវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល ឬក៏ក្នុងការចូលរួមក្នុងពិធីជាផ្លូវការផ្សេងៗ។ មួយវិញទៀត គោលគំនិតនៃ "សង្គមស៊ីវិល" នៅមិនទាន់មានការយល់ដឹងជាទូទៅ ឬយល់ដឹងបានស្មើៗគ្នានៅតាមតំបន់ទីប្រជុំជនទេ ហើយជាក់ស្ដែងតួនាទី "សង្គមស៊ីវិល" នេះកម្រមានឮសួរគេលើកឡើងណាស់ នៅតាមសង្កាត់ទីក្រុងក្នុងខេត្តកំពត ប៉ុន្តែមានគេលើកឡើងជារឿយៗនៅតំបន់ទីក្រុងក្នុងខេត្តបាត់ដំបង។

## **ការស្រាវជ្រាវស្នើឡើងដោយ** CDRI

ដោយពិនិត្យឃើញចន្លោះខ្វះខាតផ្នែកចំណេះដឹងនេះ CDRI បានរចនារៀបចំការសិក្សាមួយ ដើម្បីពិនិត្យពីអភិបាលកិច្ចតំបន់ទីប្រជុំជននៅកម្ពុជា ក្រោយធ្វើវិមជ្ឈការ។ ការស្រាវជ្រាវនេះព្យាយាមឆ្លើយតបនឹងសំណួរ៖ តើគោលនយោបាយវិមជ្ឈការជះឥទ្ធិពលយ៉ាងដូចម្ដេចទៅលើ អភិបាលកិច្ចតំបន់ទីប្រជុំជននៅកម្ពុជា? ការស្រាវជ្រាវនេះនឹងពិនិត្យថា តើកំណែទម្រង់នេះជះឥទ្ធិពលយ៉ាងណាលើគណនេយ្យភាព និងការឆ្លើយតបរបស់អាជ្ញាធរមូលដ្ឋាន ចំពោះប្រជាជន និងតើប្រជាជនមូលដ្ឋាន បានឆ្លើយតប និងចូលរួមដូចម្ដេចក្នុងដំណើរការធ្វើការសម្រេចចិត្តក្នុងបរិបទវិមជ្ឈការ។

ក្របខ័ណ្ឌស្រាវជ្រាវជាគោលគំនិតនេះបានយកចិត្តទុកដាក់ជាពិសេសលើទំនាក់ទំនងសង្គមដែលប្រែប្រួល ទៅតាមទីតាំង ថាតើទំនាក់ទំនងទាំងនោះ ជះឥទ្ធិពលយ៉ាងណាទៅលើតួអង្គនានា។ គេអាចស្វែងយល់ពី ដំណើរការដ៏ស្មុគស្មាញ និងសំខាន់ ក្នុងការតភ្ជាប់រវាងអាជ្ញាធរ និងប្រជាពលរដ្ឋបាន តាមរយៈគោលគំនិតបីសំខាន់ៗគឺ គណនេយ្យភាព ការឆ្លើយតប និង ការចូលរួម ដែលមានលើកឡើងជារឿយៗ នៅក្នុងការសិក្សាមានស្រាប់នានាស្ដីពីអភិបាលកិច្ច និងវិមជ្ឈការ។ ការសិក្សានេះបានវិភាគលើគោលគំនិតទាំងបីខាងលើ ព្រមទាំងបូកបញ្ចូលនូវការយកចិត្តទុកដាក់ពីទីតាំង ពោលគឺដោយមានការយល់ដឹងថា គំនិតចម្បងទាំងបីនេះ កំពុងកើតឡើងនៅក្នុងលំហកន្លែងតូចចង្អៀត ដែលជាលក្ខណៈធម្មតានៃតំបន់ទីប្រជុំជន ដែលខុសពីតំបន់ជនបទមានកន្លែងលំហធំទូលាយ។ ជាការសំខាន់ណាស់ដែលត្រូវមើលឃើញថា លំហគឺជាចំនុចផ្ដោតនៃគោលគំនិតទាំងនេះ គឺមិនមែនដូចក្នុងការយល់ឃើញជាទូទៅដែលថា លំហគឺជាកន្លែងដែលគោលគំនិតទាំងនេះស្ដែងឡើងនោះទេ។ ការចូលរួមក្នុងការអភិវឌ្ឍ និងកិច្ចការនយោបាយនៅមូលដ្ឋាន ជាទិដ្ឋភាពដ៏សំខាន់បំផុតមួយនៃវិមជ្ឈការបែបប្រជាធិបតេយ្យ ព្រោះបានអនុញ្ញាតឲ្យប្រជាពលរដ្ឋចូលរួម និងបញ្ចេញសំឡេង/ចំណង់ចំណូលចិត្តរបស់ខ្លួនស្ដីពីតម្រូវការនិងការអភិវឌ្ឍក្នុងសហគមន៍។ នៅពេលប្រជាជនមូលដ្ឋាន មានឱកាសចូលរួមក្នុងការកំណត់គម្រោង និងធ្វើផែនការថវិកានោះ ពួកគេទទួល បានព័ត៌មានច្រើនជាងមុនអំពីសកម្មភាពរបស់ថ្នាក់ដឹកនាំ/ក្រុមប្រឹក្សា និងមានអារម្មណ៍ជាម្ចាស់កាន់តែខ្ពស់ (Heng *et al.* 2011)។

គណនេយ្យភាព សំដៅដល់ ការទទួលខុសត្រូវលើសកម្មភាពនានា (Grindle 2011; Kim 2012)។ គេអាចកំណត់និយមន័យវាថាជា កាតព្វកិច្ចត្រូវឆ្លើយបំភ្លឺនិងទទួលខុសត្រូវលើសកម្មភាពនានា ដោយផ្អែកលើក្របខ័ណ្ឌជាក់លាក់មួយ (Kim & Ojendal

*(តទៅទំព័រ ២១)*

*តពីទំព័រ ១៤* **អភិបាលកិច្ចទីប្រជុំជន...**

2012) ឬការប្រើប្រាស់សិទ្ធិអំណាច (Moncrieff 2001)។ យ៉ាងហោចណាស់មានកត្តាបី ដែលប្រជាជនគួរចាប់ឲ្យមន្ត្រីជាប់ឆ្នោតមានគណនេយ្យភាព លើសកម្មភាពផ្សេងៗរបស់ខ្លួន៖ (១) ប្រជាជនអាចប្រើប្រាស់សំឡេងឆ្នោតយ៉ាងសក្តិសិទ្ធិ ដើម្បីផ្តល់រង្វាន់ ឬដាក់ទណ្ឌកម្ម ចំពោះការអនុវត្តជាទូទៅ ឬជាក់លាក់របស់មន្ត្រី (២) ប្រជាពលរដ្ឋអាចបង្កើតឲ្យមានចម្លើយតបចំពោះតម្រូវការរួមរបស់ខ្លួន ពីសំណាក់អាជ្ញាធរមូលដ្ឋាន និង (៣) ប្រជាពលរដ្ឋ អាចមានទំនុកចិត្តបានថាខ្លួនទទួលបានចំណាត់ការប្រកបដោយយុត្តិធម៌ និងសមធម៌ពីសំណាក់ទីភ្នាក់ងារសាធារណៈនៅកម្រិតមូលដ្ឋាន (Grindle 2011)។ នៅក្នុងវាក្យស័ព្ទនៃវិមជ្ឈការបែបប្រជាធិបតេយ្យនៅកម្ពុជា ពាក្យនេះសំដៅដល់ គណនេយ្យភាពបីប្រភេទខុសៗគ្នា គឺ៖ គណនេយ្យភាពពីក្រោមទៅលើ តាមខ្សែបណ្តោយ និង ពីលើចុះក្រោម (Hughes & Devas 2007; Kim 2012; Kim & Ojendal 2007)។

ការឆ្លើយតប សំដៅដល់សមត្ថភាពរបស់អាជ្ញាធរក្នុងការបំពេញតាមការសន្យារបស់ខ្លួន (មិនមែនគ្រាន់តែបង្កើនការរំពឹងទុករបស់ប្រជាពលរដ្ឋអ្នកបោះឆ្នោតនោះទេ)។ ការឆ្លើយតបជាលទ្ធភាពក្នុងការបំពេញតាមសំណើរបស់ប្រជាជន ដូចជាលទ្ធផលជាក់ស្តែង និងសេវាកម្មនៅមូលដ្ឋានជាដើម។ ដូច្នេះវាជាការទទួលខុសត្រូវចំពោះផលប្រយោជន៍ក្នុងមូលដ្ឋាន ដែលនៅកម្ពុជា វាតម្រូវឲ្យមានការយល់ដឹងពីស្ថានភាពនៅមូលដ្ឋាន (Kim 2012)។ Manor បានកំណត់ការអនុវត្តទំនួលខុសត្រូវជាបីយ៉ាង៖ (១)ល្បឿននៃការឆ្លើយតបតាមធម្មតាតែងកើនឡើង ព្រោះក្រុមប្រឹក្សាជាប់ឆ្នោតនៅកម្រិតទាប គឺមានអំណាចឯករាជ្យគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាយ៉ាងលឿន ក៏ដូចជាសំណូមពរផ្សេងៗរបស់ប្រជាជន (២) បរិមាណនៃការឆ្លើយតប ក៏តែងកើនឡើងដែរ ព្រោះក្រុមប្រឹក្សាទំនងផ្តោតលើគម្រោងតូចៗ ច្រើនជាងគម្រោងធំៗ និង (៣) គុណភាពនៃការឆ្លើយតប តែងល្អប្រសើរឡើង ប្រសិនបើគុណភាពនោះត្រូវវាស់វែងទៅតាមកម្រិតស៊ីគ្នាល្អរវាងចម្លើយតបរបស់រដ្ឋាភិបាល និងតំរូវការរបស់ប្រជាជន។

## សន្និដ្ឋាន

អត្ថបទនេះរកឃើញថា ភាគច្រើន អភិបាលកិច្ចតំបន់ទីក្រុងមិនសូវទទួលបានការយកចិត្តទុកដាក់ទេ នៅក្នុងក្របខ័ណ្ឌវិមជ្ឈការបែបប្រជាធិបតេយ្យជារួមនៅកម្ពុជា ទាំងខាងផ្នែកគោលនយោបាយ និងផ្នែកស្រាវជ្រាវ។ ដោយសារនគរូបនីយកម្មកម្ពុជាកំពុងលូតលាស់ទៅមុខយ៉ាងលឿន ដូច្នេះគួរមានជាបន្ទាន់នូវគោលនយោបាយវិមជ្ឈការមួយដែលបានគិតគូរល្អដល់ ភាពខុសប្លែកគ្នាខាងទីតាំងភូមិសាស្ត្រ លំហកន្លែង និងលក្ខខណ្ឌសេដ្ឋកិច្ច-សង្គមកិច្ច។ នគរូបនីយកម្មនៅកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ ហេតុនេះនៅមានលទ្ធភាពច្រើនដើម្បីធានាឲ្យអភិបាលកិច្ចទីប្រជុំជនទទួលបានជោគជ័យ។ ដូច្នេះឥឡូវនេះ គេគួរបង្កើនការយកចិត្តទុកដាក់លើ ការបណ្តុះបណ្តាល និងបំពាក់បំប៉នអាជ្ញាធរមូលដ្ឋាននៅតំបន់ទីប្រជុំជនឲ្យបានកាន់តែប្រសើរ ព្រមទាំងផ្តល់ឧបករណ៍ និងធនធានឲ្យបានសមស្រប ដើម្បីដោះស្រាយបញ្ហាដែល តែងកើតមាននៅក្នុងទីក្រុងធំៗ ដូចជា ការស្ទះចរាចរណ៍ ការបំពុលបរិស្ថាន និងសំណង់អនាធិបតេយ្យជាដើម។ ដោយមានការយកចិត្តទុកដាក់ពីបញ្ហាលំហនិងទីតាំង គម្រោងអភិបាលកិច្ចតំបន់ទីប្រជុំជននេះគឺជាគំនិតផ្តួចផ្តើមតូចមួយ ដើម្បីរួមចំណែកបង្កើនចំណេះដឹង និងផ្តល់ព័ត៌មានដល់ការជជែកវែកញែកអំពី កំណែទម្រង់វិមជ្ឈការនៅកម្ពុជា ទាក់ទងនឹងភាពបន្ទាន់ ភាពសម្បូរបែប និង ចម្លើយតបខាងគោលនយោបាយ។

## ឯកសារយោង


Benghong, S.K. (2006), “Cambodia” in B. Roberts & T. Kanaley (eds.), *Urbanisation and Sustainability in Asia: Case Studies of Good Practice* (Manila: Asia Development Bank) pp.71-100

Blunt, P., & Turner, M. (2005),”Decentralization, Democracy and Development in a Post-Conflict Society: Commune Councils in Cambodia”, *Public Administration and Development*, Vol. 25, pp. 75-87

Chheat S., Lun P., Kim S., Heng S., Sok S. & Chhoun N. (2011), *A Baseline Survey of Sub-national Government: Towards a Better Understanding of Decentralisation and Deconcentration in Cambodia,* Speical Issue 12 (Phnom Penh: CDRI)

Devas, N. (2004), *Urban Governance, Voice and Poverty in the Developing World* (London: Earthscan)

Grindle, M. S. (2011, *Sanctions, Benefits and Rights: Three Faces of Accountability,* Working Paper 4 (Visby, Sweden:ICLD)

Gutkind, P.C. (1974), *Urban Anthropology: Perspectives on ‘Third World’ Urbanization and Urbanism* (New York: Barnes and Noble Books)

Hughes, C. & N. Devas (2007), *Review of the Draft Law on Administration and Management of the Capital, Province, Municipality, District, Khan* (unpublished)

Kaufman, D., F. Leautier & M. Mastruzzi (2005), *Governance and the City: An Empirical Exploration into Global Determinants of Urban Governance* , Policy Research Working Paper 3712 (Washington, DC: World Bank Institute)

Kim, N. & R. Henke (2005), *Commune Councils in Cambodia: A National Survey on their Functions and Performance, with a Special Focus on Conflict Resolution* (Phnom Penh: Asia Foundation)


ឯកសារយោងមួយចំនួនទៀត មានចុះនៅក្នុងអត្ថបទជាភាសាអង់គ្លេស